ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ ០៩៧/១៩ ...អបស/ស៧

ថ្ងៃ ចន្ទ ៣រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែ មេសា ឆ្នាំ២០១៩

# ប្រកាស

## ស្តីពី

## បែបបទ និងលក្ខខណ្ឌបច្ចេកទេស
## ក្នុងការសុំបើក ឬបិទ ឬប្តូរទីតាំង បន្ទប់ថែទាំជំងឺមាត់-ធ្មេញឯកជន

# រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ សនរកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០ ប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៥/៣៩៦ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈទន្តពេទ្យកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣៧៣ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៧ ស្តីពីការបង្កើតគណៈគិលានុបដ្ឋាកកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីបែបបទនិងល័ក្ខខ័ណ្ឌ នៃការអនុញ្ញាតឲ្យជនបរទេសជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ប្រកបវិជ្ជាជីវៈឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសុខាភិបាល។





Scanned with CamScanner

# សម្រេច

**ប្រការ ១.-**

ការបើក ការបិទ ការប្តូរទីតាំង ការបន្តសុពលភាព បន្ទប់ថៃទាំជំងឺមាត់-ធ្មេញ អាចប្រព្រឹត្តទៅបានលុះត្រា តែមានការអនុញ្ញាតពីមន្ទីរសុខាភិបាលរាជធានី-ខេត្ត។

**ប្រការ ២.-**

មន្ទីរសុខាភិបាលរាជធានី-ខេត្ត មានសិទ្ធិព្រមាន ឬ ផ្អាក ឬបញ្ឈប់ការបើកសេវា បន្ទប់ថៃទាំជំងឺមាត់-ធ្មេញ ក្នុងករណីពិនិត្យឃើញថា៖

១-សាមីជនរៀបចំសេវាមិនសមស្របតាមលក្ខខណ្ឌកំណត់របស់ក្រសួងសុខាភិបាល

២-សាមីជនមិនគោរពតាមកិច្ចសន្យា និងការណែនាំរបស់ក្រសួងសុខាភិបាល

៣-សាមីជនមានទោសពីបទល្មើសព្រហ្មទណ្ឌកម្រិតមជ្ឈិម ឬឧក្រិដ្ឋ។

**ប្រការ៣.-**

សំណុំលិខិតសុំបើក បន្ទប់ថៃទាំជំងឺមាត់-ធ្មេញ មាន ៖

| | |
|---|---|
| ១-ពាក្យសុំបើកសេវា "មានគំរូ" | ០១ច្បាប់ |
| ២-ជីវប្រវត្តិសង្ខេបរបស់សាមីជន " មានគំរូ " | ០១ច្បាប់ |
| ៣-កិច្ចសន្យារបស់សាមីជន " មានគំរូ " | ០១ច្បាប់ |
| ៤-វិញ្ញាបនបត្រសុខភាព ចេញដោយក្រសួងសុខាភិបាល ឬមន្ទីរពេទ្យរដ្ឋ | ០១ច្បាប់ |
| ៥-គំនូសបំព្រួញទីតាំងដោយមានបញ្ជាក់ពីឃុំ/សង្កាត់ | ០១ច្បាប់ |
| ៦-សញ្ញាប័ត្រដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល ឬក្រសួងអប់រំយុវជននិងកីឡា ថាត្រឹមត្រូវ (ដោយបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចថាបានចំឡងត្រឹមត្រូវតាមច្បាប់ដើម) | ០១ច្បាប់ |
| ៧-លិខិតបញ្ជាក់ថាបានចុះឈ្មោះក្នុងគណៈគិលានុបដ្ឋាក | ០១ច្បាប់ |
| ៨-ទម្រង់របាយការណ៍ HC1 " មានគំរូ " | ០១ច្បាប់ |
| ៩-រូបថតសាមីជន (បច្ចុប្បន្ន) ៤ X ៦ ស.ម ចំនួន | ០៧សន្លឹក |
| ១០-រូបថតបន្ទប់ថៃទាំជំងឺមាត់-ធ្មេញជាប់ជាមួយស្លាកសញ្ញា ចំនួន | ០១សន្លឹក |

**ប្រការ ៤.-**

សំណុំលិខិតសុំប្តូរទីតាំង បន្ទប់ថៃទាំជំងឺមាត់-ធ្មេញ មាន ៖

| | |
|---|---|
| ១-ពាក្យសុំប្តូរទីតាំង "មានគំរូ" | ០១ច្បាប់ |
| ២-ជីវប្រវត្តិសង្ខេបរបស់សាមីជន "មានគំរូ" | ០១ច្បាប់ |
| ៣-កិច្ចសន្យារបស់សាមីជន "មានគំរូ" | ០១ច្បាប់ |
| ៤-វិញ្ញាបនបត្រសុខភាព ចេញដោយក្រសួងសុខាភិបាល ឬមន្ទីរពេទ្យរដ្ឋ | ០១ច្បាប់ |
| ៥-គំនូសបំព្រួញទីតាំងដោយមានបញ្ជាក់ពីឃុំ/សង្កាត់ | ០១ច្បាប់ |
| ៦-សញ្ញាប័ត្រដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល ឬក្រសួងអប់រំយុវជននិងកីឡា ថាត្រឹមត្រូវ (ដោយបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចថាបានចំឡងត្រឹមត្រូវតាមច្បាប់ដើម) | ០១ច្បាប់ |



Scanned with CamScanner

៧-លិខិតបញ្ជាក់ថាបានចុះឈ្មោះក្នុងគណៈគិលានុបដ្ឋាក ០១ច្បាប់
៨-ទម្រង់របាយការណ៍ HC1 " មានគំរូ " ០១ច្បាប់
៩-រូបថតសាមីជន (បច្ចុប្បន្ន) ៤ X ៦ ស.ម ចំនួន ០៧សន្លឹក
១០-រូបថតបន្ទប់ថែទាំជំងឺមាត់-ធ្មេញជាប់ជាមួយស្លាកសញ្ញា ចំនួន ០១សន្លឹក

**ប្រការ ៥.-**

អាចបើកបន្ទប់ថែទាំជំងឺមាត់-ធ្មេញ បានចំពោះតែ ទន្តគិលានុបដ្ឋាក ដែលបាន ចុះឈ្មោះជាសមាជិកគណៈគិលានុបដ្ឋាក និងគោរពតាមលក្ខខណ្ឌដូចខាងក្រោមនេះ ៖

១-មានស្លាកសញ្ញាជាបន្ទប់ថែទាំជំងឺមាត់-ធ្មេញ ដែលបានកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល
២-មានកន្លែងរង់ចាំ ដែលមានទំហំយ៉ាងតូច ៨ម² និងមានកៅអី ឬសាឡុងសម្រាប់រង់ចាំ
៣-មានសៀវភៅសម្រាប់កត់ត្រាពីសកម្មភាពនៃការថែទាំជំងឺមាត់-ធ្មេញប្រចាំថ្ងៃ
៤-មានបន្ទប់ថែទាំជំងឺដែលមានទំហំយ៉ាងតូច ១២ម²
៥-មានកៅអីធ្មេញ១ ដោយមានពន្លឺអគ្គិសនីសម្រាប់បំភ្លឺត្រឹមត្រូវ និងមានទឹកស្អាតខ្ពុរមាត់
៦-មានឡាវ៉ាបូ និងសាប៊ូសម្រាប់លាងដៃ និងមានបិទរូបភាពលាងដៃ ឬអាល់កុល
៧-មានកន្លែងលាងសម្ភារៈ និងឆ្នាំងស្ងោរសម្លាប់មេរោគ (Presser Cooker) ឬ Autoclave លើសម្ភារៈដែលត្រូវប្រើឡើងវិញ
៨-មានធុងសំរាមបីប្រភេទៈ សំណល់ទូទៅ (ធុងពណ៌បៃតង) សំណល់ឆ្លងរោគ (ធុងពណ៌លឿងមានស្លាកពណ៌ខ្មៅ) និងសំណល់មុតស្រួច ឬប្រអប់សុវត្ថិភាពសម្រាប់ដាក់វត្ថុមុតស្រួច ឬកំប៉ុងដាក់វត្ថុមុតស្រួចព័ត៌មាន លម្អិតសូមអានប្រកាសស្តីពីការគ្រប់គ្រងសំណល់ពីសេវាថែទាំសុខភាព កាកសំណល់ឆ្លងរោគមុតស្រួចត្រូវដុតកំទេច
៩-មានកន្លោរ និងចង្ក្រានសម្រាប់ដុតសំណល់ឆ្លងរោគ ឬវត្ថុមុតស្រួច
១០-មានកូនទូតូច១ដាក់ឱសថនៅក្នុងបន្ទប់ថែទាំជំងឺមាត់-ធ្មេញ និងបរិក្ខារពេទ្យប្រើប្រាស់សមស្រប
១១-មានតារាងតម្លៃថែទាំជំងឺមាត់-ធ្មេញត្រឹមត្រូវ
១២-ត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីសកម្មភាពថែទាំជំងឺមាត់-ធ្មេញតាមគេហទំព័ររបស់នាយកដ្ឋានផែនការ ឬផ្ញើមកការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ឬមន្ទីរសុខាភិបាលរាជធានី-ខេត្ត
១៣-មិនអនុញ្ញាតដាក់តាំងលក់ឱសថក្នុងបន្ទប់ថែទាំជំងឺមាត់-ធ្មេញជាដាច់ខាត។

**ប្រការ ៦.-**

បន្ទប់ថែទាំជំងឺមាត់-ធ្មេញ ធ្វើការងារ ៖

១-ការព្យាបាលមាត់-ធ្មេញបន្ទាន់ៈ (OUT: Oral Urgent Treatment)

- ការព្យាបាលសម្រន់ដើម្បីកាត់បន្ថយនូវការឈឺចាប់
- ព្យាបាលបន្ទាន់នូវការបង្ករោគ ឬគ្រោះថ្នាក់ផ្នែកមុខ មាត់-ធ្មេញ ឆ្អឹងថ្គាម
- ផ្តល់ថ្នាំបំបាត់ការឈឺចាប់
- ដកចេញនូវធ្មេញដែលពុកខ្លាំង



Scanned with CamScanner

- កោសសំអាត និងព្យាបាលជំងឺអញ្ចាញធ្មេញកម្រិតស្រាល
- ទប់ស្កាត់នូវបញ្ហាដែលកើតមានឡើងនៅពេលក្រោយដកធ្មេញ ដូចជាការហូរឈាមរលាករណ្ដៅធ្មេញ ឬការបង្ករោគ
- ការបង្ករោគដោយបញ្ហាមាត់-ធ្មេញ
- វះបង្ហូរខ្ទុះចំពោះបូសធ្មេញដែលកើតមាន
- ចំណាត់ការបញ្ជូននូវករណីដែលធ្ងន់ធ្ងរនិងស្មុគស្មាញទៅកន្លែងដែលមានជំនាញឯកទេស។

២-ការបិទប៉ះធ្មេញដោយឧបករណ៍ប្រើនឹងដៃ (ART) លើធ្មេញពុកកម្រិតទី១ និងទី២ ។

៣-ការអប់រំសុខភាពមាត់-ធ្មេញ ជាពិសេសដល់ក្រុមស្ត្រីមានផ្ទៃពោះ និងកុមារះ

- ការដុសសម្អាតធ្មេញដោយប្រើថ្នាំដុសធ្មេញមានសារធាតុភ្លុយអរ
- ការបិទប៉ះចង្អូរធ្មេញថ្គាមកុមារ
- ការលាបសារធាតុភ្លុយអរដល់ធ្មេញកុមារ។

**ប្រការ ៧.-**

ការផ្ដល់លិខិតអនុញ្ញាតច្បាប់ជូនដល់ បន្ទប់ថែទាំជំងឺមាត់-ធ្មេញ គឺផ្ដល់ជូនច្បាប់អនុញ្ញាតរយៈពេល ៣ឆ្នាំម្ដង និងមានផ្ដល់ជូនស្លាកសញ្ញាសំគាល់ Logo ស្របច្បាប់ ដោយមានចុះលេខបញ្ជិកាសំគាល់ពីមន្ទីរសុខាភិបាលរាជធានី-ខេត្ត។

**ប្រការ ៨.-**

បន្ទប់ថែទាំជំងឺមាត់-ធ្មេញ ដែលទទួលបានច្បាប់អនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈហើយ ត្រូវធ្វើរបាយការណ៍អំពីសកម្មភាពព្យាបាលជំងឺរៀងរាល់ ៣ខែម្ដង មកក្រសួងសុខាភិបាល តាមរយៈការិយាល័យ សុខាភិបាលស្រុកប្រតិបត្តិ ឬមន្ទីរសុខាភិបាលរាជធានី-ខេត្តឱ្យបានទៀងទាត់។ ករណីមិនគោរពតាមប្រការនេះ មន្ទីរសុខាភិបាលរាជធានី-ខេត្ត នឹងផ្អាកសកម្មភាពសេវា និងដកយកលិខិតអនុញ្ញាតវិញ ព្រមទាំងមិនអនុញ្ញាតច្បាប់នៅពេលសុំបន្តសុពលភាព។

**ប្រការ ៩.-**

បន្ទប់ថែទាំជំងឺមាត់-ធ្មេញ ដែលបានទទួលការអនុញ្ញាតឱ្យបើកពីមុនមក ត្រូវមកបំពេញបន្ថែមនូវទម្រង់បែបបទនិងរៀបចំទីតាំងឱ្យមានលក្ខណៈសមស្របតាមប្រកាសនេះឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិនៃច្បាប់។

**ប្រការ ១០.-**

បន្ទប់ថែទាំជំងឺមាត់-ធ្មេញ ត្រូវបង្កលក្ខណៈគ្រប់បែបយ៉ាងដល់ការត្រួតពិនិត្យរបស់គណៈកម្មាធិការ ឬភ្នាក់ងារត្រួតពិនិត្យក្រសួងសុខាភិបាល ឬមន្ទីរសុខាភិបាលរាជធានី-ខេត្ត។

**ប្រការ ១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។



Scanned with CamScanner

**ប្រការ ១២.-**

នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសុខាភិបាលដែលពាក់ព័ន្ធត្រូវអនុវត្ត តាមប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

<u>កន្លែងទទួល</u>
-ទីស្តីការគណៈរដ្ឋមន្ត្រី
-សាលារាជធានី-ខេត្ត
-គណៈវិជ្ជាជីវៈសុខាភិបាលថ្នាក់ជាតិ និងរាជធានី-ខេត្ត
-មន្ទីរសុខាភិបាលរាជធានី-ខេត្ត (ដើម្បីអនុវត្ត)
-ដូចប្រការ១២
-ឯកសារ-កាលប្បវត្តិ



Scanned with CamScanner